# ការសុគតជំនួស (ធួននឹងបាប ឬ ការស្លាប់ដើម្បីរំលោះបាប)

## The Atonement

អ្នកនិពន្ធ រ៉ូហ្វ លេភិឡារ

## *ឈើឆ្កាង និងការសុគតជំនួស (ធួននឹងបាប ឬ ការស្លាប់ដើម្បីរំលោះបាប) គឺជាចំនុចស្នូលនៃព្រះគម្ពីរ* The Centrality of the Cross and Atonement

**សង្ខេប៖** ការសុគតរបស់ព្រះយេស៊ូវនៅលើឈើឆ្កាងគឺជាចំនុចស្នូលនៃគោលបំណងដ៏អស់កល្បជានិច្ចរបស់ព្រះនិងជារាជសារនៃព្រះគម្ពីរ។ មនុស្សចាំបាច់ត្រូវទុកចិត្តលើអ្វីដែលព្រះយេស៊ូវបានធ្វើនៅលើឈើឆ្កាង ហើយគ្រីស្ទបរិស័ទចាំបាច់ត្រូវស្វែងយល់នូវអ្វីដែលទ្រង់បានធ្វើនៅលើឈើឆ្កាង។

**ការពិភាក្សា** ឈើឆ្កាងក្លាយជានិមិត្តរូបនៃជំនឿគ្រីស្ទបរិស័ទ។ ហេតុអ្វី?

### ឈើឆ្កាង និងបេសកកម្មរបស់ព្រះគ្រីស្ទ

មានអត្ថបទច្រើនដែលបង្ហាញថា បេសកកម្មរបស់ព្រះគ្រីស្ទ (មូលហេតុដែលទ្រង់បានយាងមកផែនដី) គឺប្រយោជន៍ដើម្បីទ្រង់នឹងសុគតនៅលើឈើឆ្កាង។ ឧទាហរណ៍ យ៉ូហាន ១:២៩ ប្រាប់ថា ទ្រង់មានបេសកកម្មក្នុងការដោះយកបាបចេញ។ យ៉ូហាន ១២:២៣-៣៣ បញ្ជាក់ប្រាប់ថា នៅចុងបញ្ចប់នៃជីវិតរបស់ទ្រង់លើផែនដី ទ្រង់នៅតែមើលឃើញបេសកកម្មរបស់ទ្រង់នៅអនាគត។ រីឯមនុស្សធម្មតាគេបានសម្រេចគោលបំណងនៅចុងបញ្ចប់ជីវិតហើយ តែប្រសិនបើគេមិនទាន់បានសម្រេចនោះ ឥឡូវនេះវាហួសពេលហើយ ពីព្រោះគេស្ទើរតែស្លាប់ហើយ។ ប៉ុន្តែព្រះគ្រីស្ទវិញ ជីវិតរបស់ទ្រង់លើផែនដីជិតអស់ហើយ ប៉ុន្តែទ្រង់មិនទាន់បានសម្រេចបេសកកម្មរបស់ទ្រង់នៅឡើយ ពីព្រោះបេសកកម្មនោះគឺថា ទ្រង់ត្រូវសុគតនិងរស់ឡើងវិញ។ ម៉ាថាយ ២៦:២៦-២៨ ជាទីរំលឹកអំពីការសុគតរបស់ទ្រង់។ សូមមើលផងដែរ៖

១កូរិន. ១៥:៣-៤

លូកា ២៤:២៥-២៧; ៤៤-៤៧

១កូរិន. ១:១៨-២៥ មិនមានអ្វីខ័ណ្ឌចែកសាសនាទាំងឡាយជាងឈើឆ្កាងនោះទេ។

នៅពេលដែលយើងសិក្សាអំពីការសុគតជំនួស នោះយើងកំពុងតែស្ថិតនៅចំចំណុចកណ្តាលនៃគោលបំណងដ៏អស់កល្បជានិច្ចរបស់ព្រះហើយ។ លើសពីនេះទៅទៀត ឈើឆ្កាងជារាជសារនៃព្រះគម្ពីរ។ ការសុគតជំនួសគឺជាចំណុចស្នូលនៃព្រះគម្ពីរ ហើយគោលលទ្ធិផ្សេងៗនឹងហូរចូលក្នុងការយល់ដឹងរបស់យើងអំពីការសុគតជំនួស ហើយការយល់ដឹងអំពីការសុគតជំនួសនេះក៏មានអានុភាពលើគោលលទ្ធិផ្សេងទៀតដល់យើងដែរ។ អាស្រ័យហេតុនេះ បើសិនជាមានអ្នកណាមិនយល់អំពីឈើឆ្កាង នោះអ្នកនោះក៏មិនអាចយល់អំពីព្រះគម្ពីរ អំពីព្រះគ្រីស្ទឬក៏ជំនឿគ្រីស្ទបរិស័ទដែរ។ បើសិនជាមានអ្នកណាយល់ខុសពីឈើឆ្កាង អ្នកនោះនៅតែមិនយល់ត្រឹមត្រូវអំពីព្រះគ្រីស្ទនិងជំនឿគ្រីស្ទបរិស័ទដែរ។

## *ហេតុអ្វីបានជាព្រះគ្រីស្ទត្រូវសុគត?* Why did Christ die?

ការសុគតរបស់ព្រះយេស៊ូវមកពីហេតុរបស់មនុស្សដែលជំរុញអោយគេសម្លាប់ទ្រង់ (កត្តាមកពីមនុស្ស) និងមកពីផែនការណ៍របស់ព្រះជាម្ចាស់ (កត្តាមកពីព្រះ) ផងដែរ។

### កត្តាមកពីមនុស្ស

១. លូកា ២៣:១-២៥ លោកពីឡាត់បានព្យាយាមគេចវាសពីការសម្លាប់ព្រះយេស៊ូវ ប៉ុន្តែគាត់អនុញ្ញាតឲ្យគេឆ្កាងព្រះយេស៊ូវដើម្បីបំពេញចិត្តហ្វូងមនុស្សជាជាងតាមអ្វីដែលសុចរិត។

២. ម៉ាថាយ ២៧:១៨ សាសន៍យូដា និងពួកសង្ឃបញ្ជូនព្រះយេស៊ូវទៅឈើឆ្កាងពីព្រោះគេឈ្នានីសទ្រង់។

៣. យ៉ូហាន ១២:៤-៦, ម៉ាថាយ ២៦:១៤-១៦ យូដាសក្បត់ព្រះយេស៊ូវពីព្រោះគាត់ស្រឡាញ់ប្រាក់ជាជាងព្រះយេស៊ូវ។

៤. យ៉ូហាន ៧:៧ មនុស្សលោកស្អប់ព្រះយេស៊ូវពីព្រោះទ្រង់ធ្វើបន្ទាល់ពីគេថា ការប្រព្រឹត្តរបស់គេជាសេចក្តីអាក្រក់។ នៅក្នុងព័ន្ធកិច្ចរបស់ព្រះអង្គ ទ្រង់បានធ្វើបន្ទាល់បែបនេះចំពោះអ្នកសហសម័យ ហេតុនេះហើយបានជាគេបញ្ជូនព្រះយេស៊ូវទៅឈើឆ្កាង។

### មូលហេតុមកពីព្រះ

១ពេត្រុស ៣:១៨ ទ្រង់សុគតដើម្បីនាំយើងទៅឯព្រះ។ តើមនុស្សអាចចូលទៅឯព្រះដោយមិនតាមការសុគតរបស់ព្រះយេស៊ូវបានដែរឬទេ? ទេ! នេះជាមូលហេតុដែលនាំអោយទ្រង់មានបន្ទូលមុនពេលសុគតថា ទ្រង់គឺជាផ្លូវទៅឯព្រះវរបិតា គ្មានអ្នកណាទៅឯព្រះវរបិតាឡើយបើមិនតាមរយៈទ្រង់ទេនោះ។ បន្ទាប់ទៅនេះ យើងនឹងសិក្សាអំពីរបៀបដែលការសុគតរបស់ទ្រង់នាំយើងទៅព្រះ។

ម៉ាថាយ ២៦:២៨

យ៉ូហាន ១០:១១

លូកា ២៤:៤៤-៤៦

រ៉ូម ៥:៦-១១

## *កត្តាខាងគោលលទ្ធិសំខាន់ៗដើម្បីយល់ការសុគតជំនួស (ធួននឹងបាប)* Background Factors to the Atonement

### លក្ខណៈរបស់ព្រះ

ផែនការណ៍របស់ព្រះអម្ចាស់គឺ បញ្ជូនព្រះយេស៊ូវទៅឈើឆ្កាងដើម្បីតាំងទ្រង់ទុកជាទីសន្ដោសប្រោសឲ្យធួននឹងបាប ដូច្នេះហើយ យើងត្រូវយល់ឱ្យបានត្រឹមត្រូវអំពីទ្រង់ប្រយោជន៍ឱ្យយើងនឹងយល់ត្រឹមត្រូវអំពីការធួននឹងបាប។ នៅខាងក្រោមនេះ យើងនឹងសិក្សាសេចក្ដីពិតដ៏មានសារៈសំខាន់អំពីព្រះអង្គ ប្រយោជន៍ឱ្យយើងយល់ឱ្យបានត្រឹមត្រូវអំពីការធួននឹងបាបនេះ។ តើខគម្ពីរខាងក្រោមនេះបង្រៀនយើងអ្វីខ្លះអំពីព្រះ? តើការនេះជួយអោយយើងយល់អំពីសមិទ្ធផលរបស់ព្រះគ្រីស្ទនៅលើឈើឆ្កាងបានយ៉ាងដូចម្ដេចខ្លះ?
លោកុ. ៣:៨-១៩

ទំនុក. ៥០:៤

អេសេគាល ៧:៣-៤

ហូសេ ៤:៩

ដោយភាពគ្រប់លក្ខណ៍និងបរិសុទ្ធ ទ្រង់ត្រូវតែវិនិច្ឆ័យអំពើបាប។ បាបមានភាពអប្រិយខ្លាំងណាស់។ លោក Stott បានសរសេរថា ព្រះត្រូវតែមានការស្អប់ព្រះទ័យចំពោះការជំនុំជំរះរបស់ទ្រង់ចំពោះអំពើបាប។ ការដែលទ្រង់ត្រូវតែស្អប់ព្រះទ័យចំពោះអង្គទ្រង់នោះមានន័យថា ទ្រង់ត្រូវតែធ្វើជាអង្គទ្រង់និងប្រតិបត្តិតាមលក្ខណៈដ៏គ្រប់លក្ខណ៍។

## *ហេតុដែលបណ្តាលអោយព្រះជាម្ចាស់មានសេចក្តីក្រោធ*

ចោទិយកថា ៣២:១៦, ២១

យេរេមា ៣២:៣០-៣២

អេសេគាល ៨:១៧-១៨

ហូសេ ១២:១៤

ខគម្ពីរទាំងនេះបង្ហាញអោយឃើញថា នៅក្នុងលក្ខណៈរបស់ព្រះ មានប្រតិកម្មដែលបរិសុទ្ធចំពោះអ្វីដែលមិនបរិសុទ្ធ។ បើសិនជាភាពមិនបរិសុទ្ធមិនដាស់អោយទ្រង់មានកំហឹងដ៏បរិសុទ្ធទេនោះ នោះទ្រង់មិនមែនជាព្រះទេ ហើយក៏មិនអាចអោយយើងគោរពទ្រង់បានដែរ។

## *សេចក្តីខ្ញាល់ឆួលឡើង*

យ៉ូស្វេ ៧:១, ២៣:១៦
ចៅហ្វាយ ៣:៨
២សាំយ៉ូអែល ២៤:១
២ពង្សា. ១៣:៣, ២២:១៣
ហូសេ ៨:៥
ចោទិយកថា ២៩:២៤-២៨
នោះគឺជាការភ្លើងនៃកំហឹងដ៏ប្រច័ណ្ឌ
អេសេគាល ៣៦:៥-៦
នៅពេលដែលភ្លើងនៃកំហឹងឆួលឡើង នោះមិនងាយនឹងពន្លត់បានឡើយ
២ពង្សា. ២៣:២៦
យេរេមា ២១:១២
នៅពេលដែលកំហឹងរបស់ព្រះយេហូវ៉ាឆេះឡើង ភ្លើងនោះនឹងបញ្ឆេះដល់អស់អ្នកដែលត្រូវទទួល
ជនគណនា ១១:១
ចោទិយ. ៦:១៥
ទំនុក. ៥៩:១៣
ភ្លើងនៃកំហឹងរបស់ទ្រង់នឹងត្រូវបានពន្លត់  លុះត្រាតែការវិនិច្ឆ័យនឹងត្រូវបានបំពេញ
យ៉ូស្វេ ៧:២៦

អេសេគាល ៥:១៣

### *ការស្កប់ព្រះទ័យ*

មានពាក្យមួយចំនួនដែលបង្ហាញថា ព្រះត្រូវតែស្កប់ព្រះទ័យនឹងអង្គទ្រង់។ ពាក្យមួយគឺ «kalah» ដែលមានន័យថា បាន «សំរេច» សេចក្តីក្រោធ ឬ «ដល់ទីបញ្ចប់ហើយ» ឬ «បានចំណាយហើយ»។ អេសេគាលប្រើពាក្យនេះជាច្រើន។

អេសេគាល ៥:១៣

៦:១២

៧:៧-៨

១៣:១៥

អ្វីដែលជាចរិតលក្ខណៈខាងក្នុងរបស់ព្រះយេហូវ៉ាត្រូវតែបង្ហាញចេញមក ហើយអ្វីដែលត្រូវបង្ហាញចេញនោះក៏ត្រូវតែចំណាយយ៉ាងពេញលេញដែរ។ នៅពេលដែលការនោះបានបញ្ចេញមកហើយ មនុស្សក៏អាចមើលឃើញនូវការបើកសំដែងរបស់ព្រះដ៏ពិតដែរ (ឌ. ៥:១៣)។

### *ព្រះនាមទ្រង់*

ព្រះប្រតិបត្តិការដោយព្រះទ័យទុកដាក់ចំពោះព្រះនាមទ្រង់ ហើយក៏អាស្រ័យដោយសារព្រះនាមទ្រង់ដែរ។ ទ្រង់ត្រូវតែបញ្ចេញសកម្មភាពដែលស្របទៅតាមលក្ខណៈរបស់ទ្រង់។

យោងតាមអេសេគាល ២០:៤៤, ៣៦:១៦-៣៨ យេរេមា ១៤:៧-២២ តើអ្វីសំខាន់បំផុតសំរាប់ព្រះយេហូវ៉ា?

ហេតុអ្វីបានជាព្រះអម្ចាស់មានព្រះហឫទ័យចង់ឱ្យរាស្ត្ររបស់ទ្រង់ដឹងពីសេចក្តីពិតនេះ?

តើនេះជួយយើងយល់អំពីការធួននឹងបាបយ៉ាងដូចម្តេច?

នៅក្នុងយេរេមា ១៤ រាស្ត្ររបស់ព្រះទទួលស្គាល់ថា ពួកគេមិនអាចឈោងទៅព្រះបានដោយសារការល្អ ឬតំលៃរបស់ខ្លួននោះឡើយ ប៉ុន្តែដោយសារព្រះទ្រង់បញ្ចេញសកម្មភាពដើម្បីការពារសិរីល្អនៃព្រះនាមទ្រង់។ មានមនុស្សខ្លះរិះគិតថា ហេតុអ្វីបានជាការអត់ទោសរបស់បាបយើងអាស្រ័យទៅលើការសុគតរបស់ព្រះយេស៊ូវ? ហេតុអ្វីបានជាព្រះមិនគ្រាន់តែអត់ទោសទៅបានហើយ? ទ្រង់បង្គាប់អោយយើងអត់ទោសអោយអ្នកដ៏ទៃហើយមិនតំរូវអោយគេបង់អ្វីអោយយើងសោះមុននឹងយើងសំរេចចិត្តអត់ទោសអោយគេ។ ចុះហេតុអ្វីព្រះមិនធ្វើដូច្នោះដែរទៅ?

នៅពេលដែលមនុស្សសួរយ៉ាងដូច្នោះ ឬក៏គិតថាព្រះអាចអត់ទោសអោយយើងបានដោយមិនចាំបាច់យញ្ញបូជា នោះគេមិនបានយល់អំពីភាពធ្ងន់ធ្ងរនៃអំពើបាប ឬក៏ភាពបរិសុទ្ធនិងបារមីរបស់ព្រះនោះទេ។ នៅពេលដែលយើងមិនយល់អំពីបាបនិងសេចក្ដីបរិសុទ្ធរបស់ព្រះ នោះយើងក៏មិនយល់អំពីការសុគតជំនួសដែរ។ យើងមិនមែនជាព្រះឬក៏ជាព្រះអាទិករ ឬជាអ្នកបង្កើតច្បាប់ ឬជាចៅក្រមនៃផែនដីនេះទេ ហេតុនេះហើយយើងមិនត្រូវការទាមទារយញ្ញបូជាពីអ្នកណាទេ។ បើទ្រង់អត់ទោសដោយមិនតំរូវអោយមានដង្វាយបូជា ការនោះទាស់ប្រឆាំងនឹងលក្ខណៈជាព្រះដ៏បរិសុទ្ធរបស់ទ្រង់ហើយ។ នៅពេលមនុស្សអត់ទោសបាប នោះគឺជាកាតព្វកិច្ចសុទ្ធសាធ តែសំរាប់ព្រះគឺជាឫសកែវនៃបញ្ហាជាច្រើន។ តើព្រះដ៏បរិសុទ្ធអាចអត់ទោសអោយមនុស្សដែលបះបោរនឹងទ្រង់បានដែរទេ? ឧបសគ្គចំពោះការអត់ទោសមិនគ្រាន់តែជាបាបរបស់យើងផ្ទាល់ប៉ុណ្ណោះទេ ប៉ុន្តែគឺជាប្រតិកម្មចេញពីភាពបរិសុទ្ធរបស់ព្រះចំពោះបាប ដែលប្រតិកម្មនោះហៅថា «សេចក្ដីក្រោធ»។ យើងត្រូវតែចងចាំថា សេចក្ដីស្រឡាញ់របស់ទ្រង់ជាសេចក្ដីស្រឡាញ់ដ៏បរិសុទ្ធ។ នៅពេលដែលយើងសង្កត់ធ្ងន់ពីសេចក្ដីស្រឡាញ់របស់ព្រះ យើងមិនត្រូវធ្វើឡើងដោយរបៀបមួយដែលបន្ថយចុះការពិតដែលថា វាជាសេចក្ដីស្រឡាញ់ដ៏បរិសុទ្ធនោះឡើយ។ តើព្រះអាចសំដែងចេញសេចក្ដីស្រឡាញ់ដ៏បរិសុទ្ធរបស់ទ្រង់យ៉ាងដូចម្ដេចបាន? គឺនៅឈើឆ្កាង។ ទាល់តែពេលយើងយល់អំពីសេចក្ដីក្រោធរបស់ព្រះទើបយើងអាចយល់អំពីសេចក្ដីមេត្តារបស់ទ្រង់បាន។ ដូច្នេះការយល់ខុសអំពីគោលលទ្ធិនៃការសុគតជំនួសកើតឡើងដោយសារគោលលទ្ធិខុសឆ្គងអំពីមនុស្សឬអំពីព្រះ។

## ក្រិត្យវិន័យ

តើច្បាប់របស់ប្រទេសមួយនិងច្បាប់របស់ព្រះខុសគ្នាយ៉ាងណាខ្លះ?

តើកាឡាទី ៣:១០-១៣ បង្រៀនយើងយ៉ាងណាខ្លះអំពីសមិទ្ធផលរបស់ព្រះគ្រីស្ទនៅលើឈើឆ្កាង?

យើងត្រូវតែយល់អំពីលក្ខណៈនៃច្បាប់ដើម្បីអោយយើងអាចយល់អត្ថបទនេះបាន។ ក្រិត្យវិន័យគឺជាការបើកសំដែងនូវលក្ខណៈរបស់ព្រះនិងព្រះទ័យទ្រង់។ ការបះបោរទាស់នឹងក្រិត្យវិន័យក៏ជាការបះបោរប្រឆាំងនឹងទ្រង់ដែរ។ ព្រះបានបង្កើតក្រិត្យវិន័យ ហេតុនេះហើយបានជាទ្រង់ចាក់បណ្ដាសាមកយើងនៅពេលយើងមិនស្ដាប់បង្គាប់។ ដូច្នេះ មិនមែនក្រិត្យវិន័យទេដែលដាក់អោយយើងនៅក្រោមបណ្ដាសា ប៉ុន្តែព្រះទ្រង់ជាអ្នកដាក់យើងនៅក្រោមបណ្ដាសាវិញ ហើយក្រិត្យវិន័យគឺជាឧបករណ៍ដែលទ្រង់ប្រើប្រាស់សំរាប់ការនោះ។

## លក្ខខណ្ឌរបស់មនុស្ស

តើអេភេសូរ ២:១-៣, រ៉ូម ៣:១០-១៩, ៦:២៣, ៨:៦-៨, ១១:៣៥ បង្រៀនយើងអ្វីខ្លះអំពីមនុស្ស?

នៅក្នុងអំពើបាបរបស់យើងនៅចំពោះមុខព្រះ គ្មានអ្វីដែលយើងអាចយកធ្វើជាប្រយោជន៍ដើម្បីជួយសង្គ្រោះខ្លួនឯងយើងបានឡើយ។ ទោះបីជាយើងលះបង់ជីវិតទាំងមូលទៅចំពោះទ្រង់ នោះគ្រាន់តែជាការដែលយើងប្រគល់អោយដែលគួរតែធ្វើកាលពីដើមឡើយប៉ុណ្ណោះ ហើយបាបបានធ្វើអោយយើងធ្លាក់ចុះនិងស្ថិតក្រោមការវិនិច្ឆ័យរបស់ព្រះ។ ឧបមាថា ខ្ញុំបានខ្ចីមួយពាន់ដុល្លារពីមិត្តសម្លាញ់ ហើយក្រោយមកខ្ញុំបានសងដប់ដុល្លារវិញ។ តើមិត្តសម្លាញ់ពេញចិត្តនឹងការសងនេះឬទេ? ទេ! ការនេះសំដែងអំពីអាកប្បកិរិយារបស់មនុស្សចំពោះព្រះជាម្ចាស់។ ព្រះជាម្ចាស់ជាព្រះអាទិករដែលបានប្រទានគ្រប់ទាំងអស់ដែលយើងមាន ហើយមនុស្សគិតថា ទ្រង់សព្វព្រះហឫទ័យនៅពេលយើងថ្វាយតិចតួចឲ្យព្រះអង្គវិញ។ នៅពេលមនុស្សគិតបែបនេះ នោះបង្ហាញថា គេយល់ខុសអំពីព្រះជាម្ចាស់និងខុសអំពីខ្លួនឯងផងដែរ។ លើសពីនេះទៅទៀត ថ្វីបើយើងថ្វាយជីវិតទាំងមូលដល់ព្រះ ដង្វាយនោះមិនមានសមត្ថភាពគ្របបាំងអំពើបាបរបស់យើងទេ ពីព្រោះយើងគ្រាន់តែថ្វាយដល់ព្រះអង្គនូវអ្វីដែលទ្រង់បានប្រទានឲ្យយើងជាមុនប៉ុណ្ណោះ។ រ៉ូម ១១:៣៥ ថា
«តើអ្នកណាបានថ្វាយដល់ទ្រង់ជាមុន នោះនឹងបានប្រគល់មកអ្នកនោះវិញ»

## ព្រះគ្រីស្ទ

ព្រះយេស៊ូវត្រូវតែជាព្រះផងនិងមនុស្សផងដើម្បីសង្គ្រោះយើង។ ប្រសិនបើព្រះយេស៊ូវមិនមែនជាមនុស្ស នោះការសុគតរបស់ទ្រង់មិនមានសមត្ថភាពធ្វើជាទីសន្តោសប្រោសឲ្យធួននឹងបាបឡើយ (សូមមើលហេព្រើរ ២:១៧)។

## យញ្ញបូជានៅក្នុងសញ្ញាចាស់

ដើម្បីឱ្យយើងយល់អំពីការថ្វាយយញ្ញបូជារបស់ព្រះយេស៊ូវ នោះជាការសំខាន់ដែលយើងត្រូវយល់អំពីការថ្វាយ យញ្ញបូជានៅសញ្ញាចាស់។ គោលបំណងនៃការថ្វាយយញ្ញបូជានៅសញ្ញាចាស់គឺ នាំឱ្យយើងយល់ពីការថ្វាយយញ្ញបូជារបស់ព្រះគ្រីស្ទ។

សំនួរសំខាន់មួយដែលត្រូវសួរនោះគឺ «តើការថ្វាយយញ្ញបូជានៅសញ្ញាចាស់មានគោលបំណងអ្វី?» ឬយើងអាចសួរសំណួរប្រហែលគ្នានេះបានថា «តើការថ្វាយយញ្ញបូជានេះមានឥទ្ធិពលទៅលើអ្នកណា?» តើវាមានឥទ្ធិពលទៅលើមនុស្សមានបាប ឬមានឥទ្ធិពលទៅលើព្រះជាម្ចាស់? តើគោលបំណងនៃការថ្វាយយញ្ញបូជាគឺ ដើម្បីបំផ្លាស់បំប្រែមនុស្សមានបាប ឬដើម្បីរារាំងអ្នកនោះឱ្យលែងប្រព្រឹត្តបាបបន្តទៀត? ប្រសិនបើមានរឿងដូចនេះមែន នោះគោលបំណងនៃការថ្វាយយញ្ញបូជានឹងមានឥទ្ធិពលដល់មនុស្សមានបាបដែលថ្វាយយញ្ញបូជានោះ តែគ្មានឥទ្ធិពលទៅលើព្រះជាម្ចាស់ទេ។ ប៉ុន្តែ នេះមិនមែនជាគោលបំណងនៃយញ្ញបូជានោះទេ គោលបំណងនៃការថ្វាយយញ្ញបូជាគឺមិនមែនដើម្បីផ្លាស់ប្រែមនុស្សនោះទេ តែគឺដើម្បីព្រះវិញ។ មានន័យថា ការថ្វាយយញ្ញបូជាគឺដើម្បីឱ្យធួន នឹងបាប គឺថា សេចក្តីក្រោធរបស់ព្រះបានស្ងប់។ ព្រះគឺជាព្រះដ៏បរិសុទ្ធ ទ្រង់ត្រូវតែជំនុំជំរះអំពើបាប អំពើបាបត្រូវតែទទួលការពិន័យ ទទួលការសងថ្លៃលោះ និងទទួលទណ្ឌកម្ម។ សេចក្តីក្រោធរបស់ព្រះដែលប្រឆាំងនឹងបាបរបស់មនុស្សត្រូវបានបង្វែរចេញដោយអំពើបាបត្រូវបានសងថ្លៃលោះ។ នៅក្នុងន័យនេះ ការថ្វាយយញ្ញបូជាគឺសំរាប់ព្រះជាម្ចាស់ មានឥទ្ធិពលទៅលើព្រះជាម្ចាស់ (ហើយយើងបានទទួលការលើកលែងទោស)

យើងបានមើលឃើញភស្តុតាងនេះខ្លះៗរួចហើយ នៅក្នុងមេរៀននេះដែលមានចំណងជើងនៅខាងលើថា «ព្រះអម្ចាស់» ប៉ុន្តែប្រសិនបើចង់បានភស្តុតាងបន្ថែមទៀត នោះយើងត្រូវធ្វើការសិក្សាឱ្យបានស៊ីជំរៅទៅលើអត្ថន័យនៃពាក្យថា *ធួននឹងបាប*។ សត្វដែលគេត្រូវយកមកថ្វាយយញ្ញបូជា ត្រូវតែឥតខ្ចោះ ហើយអ្នកដែលថ្វាយយញ្ញបូជាត្រូវដាក់ដៃលើសត្វនោះ ដែលនេះគឺជានិមិត្តរូបនៃការផ្ទេរអំពើទុច្ចរិតពីមនុស្សមានបាបទៅឱ្យសត្វ។ សង្ឃជាអ្នកដែលទទួលយកដង្វាយនេះ។

## អេសាយ ៥៣

ព្រះគម្ពីរអេសាយ ៥៣ គឺជាអត្ថបទយ៉ាងសំខាន់ដើម្បីភ្ជាប់ការថ្វាយយញ្ញបូជានៅសញ្ញាចាស់ និងការថ្វាយយញ្ញបូជារបស់ព្រះយេស៊ូវគ្រីស្ទ។ នៅក្នុងជំពូកនេះ លោកអេសាយបានប្រកាសថា ព្រះយេហូវ៉ានឹងចាត់បញ្ជូនអ្នកបំរើរបស់ទ្រង់ ហើយទ្រង់នឹងផ្ទុកគ្រប់ទាំងអំពើបាបរបស់យើងនៅលើអ្នកនោះ (ខ៦)។ ដូច្នេះ អ្នកនោះគឺជាដង្វាយលោះបាប (ខ១០) មានន័យថា អ្នកនោះគឺជាអ្នកដែលទទួលផ្ទុកអំពើបាបរបស់យើងរាល់គ្នា (ខ១១-១២)។

## អត្ថន័យនៃសន្តោសប្រោស (ធួននឹងបាប) The Meaning of Atonement

**សង្ខេប៖** អត្ថន័យគ្រឹះនៃការធួននឹងបាប ដែលព្រះយេស៊ូវបានធ្វើនៅលើឈើឆ្កាង គឺជាការដែលព្រះយេស៊ូវថ្វាយអង្គទ្រង់ជាដង្វាយដើម្បីជំនួសយើងប្រយោជន៍អោយបានគ្របបាំងបាបរបស់យើងរាល់គ្នានិងបង្វែរសេចក្តីក្រោធរបស់ព្រះចេញពីយើង។

## ដង្វាយ (យញ្ញបូជា)

ការរួចផុតពីទណ្ឌកម្មរបស់អំពើបាបអាចសំរេចទៅបានដោយសារមានយញ្ញបូជាគ្របបាំងលើមនុស្សមានបាប គឺយញ្ញបូជានេះប្រៀបដូចជារនាំងខ័ណ្ឌរវាងមនុស្សមានបាបនិងទណ្ឌកម្មរបស់ព្រះ។ យញ្ញបូជាគ្របបាំងលើមនុស្សមានបាបហើយទទួលរងនូវទណ្ឌកម្មរបស់មនុស្ស។ មនុស្សមានបាបលែងមានទណ្ឌកម្មទៀតហើយពីព្រោះទណ្ឌកម្មនេះបានដាក់នៅលើយញ្ញបូជារួចហើយ។ ទណ្ឌកម្មនៃបាបគឺសេចក្តីស្លាប់ (រ៉ូម ៦:២៣) ហេតុដូចនេះហើយបានជាយញ្ញបូជាត្រូវតែស្លាប់ដើម្បីសងថ្លៃលោះបាបនេះ។ នេះហើយជាមូលហេតុដែលគេតែងតែនិយាយសំដៅទៅលើឈាម ពីព្រោះនៅក្នុងព្រះគម្ពីរ ឈាមគឺជានិមិត្តសញ្ញានៃសេចក្តីស្លាប់ (ឧ. លេវី. ១៧:៤, អេសេគាល ២២:១២)។ តែតាមពិតទៅ ឈាមរបស់សត្វមិនអាចសងថ្លៃលោះអំពើបាបរបស់មនុស្សបានឡើយ (ហេព្រើរ ១០:១១)។ ដូច្នេះហើយបានជាព្រះយេស៊ូវយាងមក ហើយបានបង្ហូរព្រះលោហិតរបស់ទ្រង់ដើម្បីលោះបាបរបស់មនុស្សទាំងអស់មួយដងជាសំរេច (ហេព្រើរ ៩:១១-១០:១៨)។ ភាពខុសប្លែកគ្នាដ៏សំខាន់មួយរវាងការថ្វាយយញ្ញបូជារបស់ព្រះយេស៊ូវគ្រីស្ទ និងការថ្វាយយញ្ញបូជារបស់ពួកសង្ឃនៅក្នុងគ្រាសញ្ញាចាស់នោះគឺ ព្រះយេស៊ូវគ្រីស្ទបានបំពេញតួនាទីទាំងពីរយ៉ាង គឺទ្រង់ផ្ទាល់ជាយញ្ញបូជាផងហើយទ្រង់ក៏ជាសង្ឃដែលថ្វាយយញ្ញបូជានោះផង។ សព្វថ្ងៃនេះគ្រីស្ទបរិស័ទមិនមានសង្ឃ ហើយយើងក៏មិនត្រូវការសង្ឃដើម្បីថ្វាយយញ្ញបូជាជំនួសយើងដូចកាលនៅគ្រាសញ្ញាចាស់ទៀតដែរ ពីព្រោះព្រះយេស៊ូវគ្រីស្ទគឺជាសំដេចសង្ឃរបស់យើងដែលបានថ្វាយ

អង្គទ្រង់ទុកជាយញ្ញបូជាមួយដងជាសំរេចរួចហើយ។ នេះហើយជាមូលហេតុដែលនៅក្នុងសញ្ញាថ្មីមិនមានកន្លែងណាមួយដែលនិយាយពីពួកសង្ឃដែលជាក្រុមមួយពិសេសក្នុងចំណោមគ្រីស្ទបរិស័ទ។ នេះក៏បានបង្ហាញឱ្យយើងមើលឃើញពីភាពខុសឆ្គងរបស់ពួករ៉ូម៉ាំងកាតូលិកដែរ ដ្បិតអី ពួកកាតូលិករហូតមកដល់សព្វថ្ងៃនេះ ពួកគេនៅតែមានសង្ឃថ្វាយយញ្ញបូជាសំរាប់សមាជិករបស់ពួកគេដដែល។

## សេចក្ដីក្រោធបែរចេញ

ភាសាក្រិកសំរាប់ពាក្យថា ធួននឹងបាបគឺ hilasterion ពាក្យនេះមានន័យថា សេចក្ដីក្រោធបែរចេញ។ នោះមានន័យថា ការថ្វាយយញ្ញបូជាគឺដើម្បីបង្វែរសេចក្ដីក្រោធរបស់ព្រះជាម្ចាស់ចេញពីមនុស្សមានបាបដោយមានការសងថ្លៃលោះអំពើបាប (ធួននឹងបាប)។ ពាក្យនេះយើងអាចមើលឃើញនៅក្នុងព្រះគម្ពីររ៉ូម ៣:២៥, ហេព្រើរ ២:១៧, ១យ៉ូហាន ២:១-២, និង ១យ៉ូហាន ៤:៨-១០ (ព្រះគម្ពីរភាសាខ្មែរប្រើពាក្យផ្សេងៗដើម្បីបកប្រែពាក្យនេះ)។ មានមនុស្សជាច្រើនមិនចូលចិត្តសេចក្ដីបង្រៀនដែលថា តាមរយៈការសុគតរបស់ព្រះយេស៊ូវគ្រីស្ទធ្វើឱ្យសេចក្ដីក្រោធរបស់ព្រះបានបែរចេញពីមនុស្ស។ ពួកគេមិនចូលចិត្តនូវគំនិតដែលថា ព្រះមានសេចក្ដីក្រោធ ឬថាទ្រង់ត្រូវការយញ្ញបូជាដើម្បីឱ្យទ្រង់បង្វែរសេចក្ដីក្រោធរបស់ទ្រង់ចេញ។ ប៉ុន្តែ សញ្ញាថ្មីបានបង្រៀនយ៉ាងច្បាស់ថា ព្រះពិតជាមានសេចក្ដីក្រោធចំពោះមនុស្សមានបាបមែន ហើយថា មានតែតាមរយៈព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះដែលមនុស្សយើងបានសង្គ្រោះឱ្យរួចពីសេចក្ដីក្រោធរបស់ទ្រង់ដែលត្រូវមកដល់នោះ (កូលូស ៣:៦, រ៉ូម ២:៥, ៥:៩, យ៉ូហាន ៣:៣៦, ១ថែស្សាឡូនិច ១:១០, ៥:៩)។ វាជាការពិតណាស់ថា តាមរយៈការថ្វាយយញ្ញបូជារបស់ព្រះយេស៊ូវគ្រីស្ទនៅលើឈើឆ្កាងនោះឯងដែលទ្រង់បានសង្គ្រោះយើងចេញពីសេចក្ដីក្រោធរបស់ព្រះជាម្ចាស់។

## ជំនួស

ការថ្វាយយញ្ញបូជានៅសញ្ញាចាស់ និងការសុគតរបស់ព្រះយេស៊ូវគ្រីស្ទអាចធួននឹងបាបរបស់មនុស្ស ពីព្រោះថាការថ្វាយយញ្ញបូជាទាំងនោះជំនួសឱ្យមនុស្សមានបាប។ នេះហើយគឺជាអត្ថន័យនៃពាក្យថា លោហិតព្រះយេស៊ូវគ្រីស្ទបានខ្ចាយជំនួសយើង។ ជាច្រើនដង នៅពេលដែលសញ្ញាថ្មីនិយាយពីលោហិតរបស់ព្រះយេស៊ូវគ្រីស្ទ គឺមិនត្រឹមតែនិយាយថា លោហិតព្រះយេស៊ូវគ្រីស្ទបានត្រូវខ្ចាយប៉ុណ្ណោះទេ ប៉ុន្តែបន្ថែមយ៉ាងនេះថា ទ្រង់បានខ្ចាយព្រះលោហិតទ្រង់ជំនួសយើងរាល់គ្នា (ម៉ាថាយ ២៦:២៨, ម៉ាកុស ១៤:២៤, លូកា ២២:២០)។ ចូរសរសេរចុះពីរបៀបដែលខគម្ពីរខាងក្រោមនេះបង្ហាញថា ព្រះយេស៊ូវគ្រីស្ទបានសុគតជំនួសយើងរាល់គ្នា។
អេសាយ ៥៣:៦

អេសាយ ៥៣:១២

២កូរិនថូស ៥:២១

កាឡាទី ៣:១៣

ហេព្រើរ ៩:២៨

១ពេត្រុស ២:២៤

យើងក៏អាចមើលឃើញដែរថា ព្រះយេស៊ូវគឺជាអ្នកសុគតជំនួស ដោយសិក្សាលើពាក្យភាសាក្រិកមួយដ៏សំខាន់ដែលពាក្យនោះត្រូវបានប្រើប្រាស់សំរាប់ពណ៌នាអំពីការងាររបស់ព្រះយេស៊ូវសំរាប់យើងរាល់គ្នាលើឈើឆ្កាងគឺ anti (ឧ. ម៉ាថាយ ២០:២៨)។ ពាក្យនេះមានន័យច្បាស់លាស់ថា instead of (ជួស) ដូចដែលបានប្រើក្នុងលូកា ១១:១១។ ដែលនិយាយថាព្រះយេស៊ូវសុគតជួសយើង គឺដូចជានិយាយថា ទ្រង់បានសុគតដូចជា អ្នករងជំនួស។

## *លទ្ធផលនៃការស្លាប់ដើម្បីរំលោះបាប (ជួននឹងបាប)* The Result of the Atonement

ចូរអានអត្ថបទខាងក្រោមនេះ ហើយសរសេរលទ្ធផលពីអ្វីដែលព្រះយេស៊ូវបានធ្វើសំរេចសំរាប់យើង។
រ៉ូម ៣:២១-២៦

រ៉ូម ៥:៩

អេភេសូរ ១:៧

អេភេសូរ ២:១១-២២

ហេព្រើរ ២:១៤-១៧

១ពេត្រុស ១:១៨-១៩

១យ៉ូហាន ១:៧

## *ទ្រឹស្តីខុសឆ្គងអំពីការស្លាប់ដើម្បីរំលោះបាប (ជួននឹងបាប)* False theories of the Atonement

**សង្ខេប៖** ទ្រឹស្តីមួយក្នុងចំណោមទ្រឹស្តីខុសឆ្គងទាំងឡាយនាបច្ចុប្បន្ននេះគឺការមិនទទួលយកថា ព្រះយេស៊ូវបានសុគតដើម្បីសងថ្លៃទណ្ឌកម្មសំរាប់បាបយើងដើម្បីបង្វែរសេចក្តីក្រោធរបស់ព្រះចេញនោះទេ។ គំនិតខុសឆ្គងទាំងនេះបណ្តាលមកពីការជឿថា ព្រះយេស៊ូវបានសុគតដើម្បីបំផ្លាស់បំប្រែមនុស្សមានបាបតែប៉ុណ្ណោះ មិនមែនសំរាប់ផ្តល់ផលប្រយោជន៍ដល់ព្រះជាម្ចាស់ឡើយ។

### ការសុគតរបស់ព្រះយេស៊ូវគ្រាន់តែជាប្រយោជន៍ទុកជាគំរូប៉ុណ្ណោះ

១ពេត្រុស ២:២០-២២ បង្រៀនថា ដោយសារការរងទុក្ខនៅឈើឆ្កាង ព្រះយេស៊ូវបានទុកគំរូឲ្យគ្រីស្ទបរិស័ទដើរតាម។ ដូច្នេះ ច្បាស់ហើយថា ការសុគតរបស់ព្រះគ្រីស្ទគឺជាគំរូឲ្យយើងតាម ប៉ុន្តែអ្នកខ្លះជឿថា ការរងទុក្ខនៅឈើឆ្កាងរបស់ព្រះយេស៊ូវ *គ្រាន់តែ* ជាគំរូ *ប៉ុណ្ណោះ*។ ទស្សនៈនេះពិតជាខុសហើយ។

### ការសុគតរបស់ព្រះយេស៊ូវគ្រាន់តែប្រយោជន៍ដើម្បីសំដែងនូវសេចក្តីស្រឡាញ់របស់ព្រះប៉ណ្ណោះ

អ្នកខ្លះជឿថា ព្រះយេស៊ូវសំដែងនូវសេចក្តីស្រឡាញ់របស់ព្រះដោយការសុគតនៅលើឈើឆ្កាង ប៉ុន្តែបដិសេធថា ព្រះយេស៊ូវបានទទួលទណ្ឌកម្មជំនួសយើងប្រយោជន៍ដើម្បីឲ្យសេចក្តីក្រោធរបស់ព្រះបែរចេញពីយើង។ ប៉ុន្តែទស្សនៈទាំងពីរនេះមិនអាចយល់ស្របគ្នាបានទេ។

ឧបមាថា មានសង្សារមួយគូបានមកលំហែកាយនៅទីចំណោទច្រាំងខ្ពស់ ហើយសង្សារមួយគូនេះបានសាសងគ្នាដោយវាចារផ្អែមល្ហែមដាក់គ្នាទៅវិញទៅមក។ ក្នុងខណៈពេលដែលពួកគេទាំងពីរនាក់កំពុងតែជជែកគ្នាផង សម្លឹងមើលទៅព្រះសុរិយាកំពុងតែអស្តង្គតផង ស្រាប់តែបុរសជាសង្សារនិយាយទៅកាន់ស្រីជាសង្សាររបស់ខ្លួនថា «បងនឹងបង្ហាញសេចក្តីស្រលាញ់ដ៏អស់អំពីចិត្តរបស់បងអោយអូនបានឃើញកាន់តែច្បាស់»។ និយាយរួចហើយបុរសនោះក៏លោតពីលើទីចំណោទចូលទៅក្នុងទឹកសមុទ្រហើយស្លាប់ទៅ ។ តើអំពើនេះបានបង្ហាញសេចក្តីស្រឡាញ់យ៉ាងដូចម្តេច? ហាក់ដូចជា អំពើនោះមិនបង្ហាញសេចក្តីស្រឡាញ់ទេ ប៉ុន្តែបង្ហាញសេចក្តីល្ងង់វិញ។ នាងងឿងឆ្ងល់ផងដែរ។ បើបងស្រឡាញ់ខ្ញុំហេតុអ្វីបានជាបងធ្វើដូចនោះ? ឥឡូវយើងនឹងប្តូរហេតុការណ៍បន្តិច។ ឧបមាថា បុរសនៅទីចំណោទច្រាំងដូច រឿងមុន ប៉ុន្តែនាងមិននៅទីចំណោទច្រាំងនៅកន្លែងឥតគ្រោះថ្នាក់ទេ ប៉ុន្តែគាត់នៅកន្លែងគ្រោះថ្នាក់ គឺនៅក្នុងទឹក ហើយ ត្រីឆ្លាមបានហែលមកបំរុងនឹងត្របាក់ខាំរូបនាងទៅហើយ។ ប៉ុន្តែបុរសជាសង្សារបានឃើញទាន់ក៏ស្រែកប្រាប់ សង្សារដ៏ជាទីស្រលាញ់របស់ខ្លួនថា « បងស្រលាញ់អូន» ហើយគាត់ក៏លោតទំលាក់ខ្លួនចំពីមុខត្រីឆ្លាម ហើយត្រីឆ្លាមក៏ត្របាក់ខាំបុរសជាសង្សារ ហើយតាមអំពើនេះគាត់បានសង្គ្រោះនាង។ តើអំពើនេះបានបង្ហាញសេចក្តីស្រឡាញ់ឬទេ? បាទ ទង្វើនេះបង្ហាញសេចក្តីស្រឡាញ់។ សំនួរមួយដ៏សំខាន់គឺ តើរូបភាពទាំងពីរនោះខុសគ្នាយ៉ាងដូចម្តេចខ្លះ? គេខុសគ្នាពីព្រោះនៅក្នុងរូបភាពទី១ ស្រីនៅកន្លែងឥតគ្រោះថ្នាក់ ប៉ុន្តែនៅក្នុងរូបភាពទី២ស្រីនៅកន្លែងគ្រោះថ្នាក់វិញ។ ព្រះគម្ពីរ

បង្រៀនយើងថា ព្រះយេស៊ូវបានបង្ហាញសេចក្ដីស្រឡាញ់ដល់ពិភពលោកដោយទ្រង់បានយាងមកផែនដីនិងសុគត។ តើហេតុអ្វីបានជាការសុគតរបស់ព្រះយេស៊ូវបានបង្ហាញអំពីសេចក្ដីស្រឡាញ់? ប្រហែលការសុគតរបស់ព្រះយេស៊ូវគឺជាភាពល្ងីល្ងើដូចនៅក្នុង រូបភាពទី១។ ប៉ុន្ដែការសុគតរបស់ព្រះយេស៊ូវមិនមែនជាភាពល្ងីល្ងើទេ ពីព្រោះការសុគតរបស់ទ្រង់សំរាប់ពិភពលោកដូចនៅក្នុងរូបភាពទី២។ នោះមានន័យថា ពិភពលោកមិនស្ថិតនៅកន្លែងឥតគ្រោះថ្នាក់ដូចស្រីនៅក្នុងរូបភាពទី១ទេ ប៉ុន្ដែស្ថិតនៅកន្លែងគ្រោះថ្នាក់ដូចស្រីនៅក្នុងរូបភាពទី២។ ពិភពលោកទាំងមូលបានបះបោរនឹងព្រះអម្ចាស់ហើយស្ថិតនៅក្រោមសេចក្ដីក្រោធរបស់ព្រះ។ គេនឹងវិនាសទៅ ប៉ុន្ដែព្រះអង្គមិនចង់ឱ្យអ្នកណាមួយវិនាសឡើយ។ ដូច្នេះហើយ ព្រះអង្គប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឱ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ។

## ទស្សនៈឥទ្ធិពលដល់សីលធម៌

Abelard បង្រៀនថាការស្លាប់របស់ព្រះយេស៊ូវមិនមានឥទ្ធិពលអ្វីដល់ព្រះទេ ប៉ុន្ដែមានឥទ្ធិពលដល់យើងវិញ។ គាត់បង្រៀនថា បាបមិនមែនជារនាំងរវាងព្រះនិងមនុស្សទេ ប៉ុន្ដែយើងផ្លាស់ប្ដូរគំនិតនៅពេលយើងមើលឃើញសេចក្ដីស្រឡាញ់នៃព្រះដែលបានសំដែងអោយឃើញនៅលើឈើឆ្កាង។ គាត់បង្រៀនថា តាមមធ្យោបាយនេះឈើឆ្កាងបានសង្គ្រោះយើងចេញពីបាប។ ម្ដងទៀត យើងប្រែប្រួលផ្លាស់ប្ដូរគំនិតនៅពេលយើងយល់អំពីសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់នៅលើឈើឆ្កាង ប៉ុន្ដែទស្សនៈនេះខុស ពីព្រោះគាត់បដិសេធថា ព្រះគ្រីស្ទជំនួសយើងដើម្បីឲ្យទ្រង់ទទួលសេចក្ដីក្រោធរបស់ព្រះអង្គចំពោះយើង។ រឿងខាងលើអំពីសង្សារមួយគូបានបង្ហាញយ៉ាងច្បាស់ថា ការសុគតរបស់ព្រះយេស៊ូវមិនសំដែងសេចក្ដីស្រឡាញ់នោះទេ បើទ្រង់មិនជំនួសយើង។

## ការបកស្រាយតាមបែបនយោបាយ

ការបកស្រាយនេះជឿថា ព្រះយេស៊ូវសុគតនៅលើឈើឆ្កាងដើម្បីសង្គ្រោះមនុស្សក្រីក្រចេញពីភាពរហេមរហាមខាងសេដ្ឋកិច្ចនិងភាពអយុត្តិធម៌ខាងនយោបាយ។ គេចាត់ទុកថា ជំនឿរបស់គ្រីស្ទបរិស័ទត្រូវតែជួយដោះស្រាយដល់បញ្ហាសេដ្ឋកិច្ចសង្គមជាចាំបាច់ តែគេមិនសូវនិយាយទាក់ទងពីរឿងខាងវិញ្ញាណ ដូចជាអំពើបាប និងការថ្វាយបង្គំរូបព្រះអីនោះទេ។ គេជឿថាព្រះយេស៊ូវបានយាងមកស្ថាបនានគរព្រះឡើង ហើយគេសង្កត់ធ្ងន់លើលទ្ធផលនៃស្ថានភាពសេដ្ឋកិច្ចនិងនយោបាយតែប៉ុណ្ណោះ។ ព្រះយេស៊ូវប្រឈមមុខហើយតតាំងនឹងកំលាំងនៃសេចក្ដីអាក្រក់នៅ *ក្នុងពិភពលោក* នេះ មិនមែនទាស់នឹងបាបនិងសេចក្ដីអាក្រក់ *របស់បុគ្គល* នោះទេ។ ទស្សនៈទាំងនេះកើតចេញពីការយល់ខុសអំពីព្រះនិងអំពីអំពើបាប។ ជាការពិតណាស់ថា ព្រះទ្រង់ស្រឡាញ់ យុត្តិធម៌និងមានព្រះហឫទ័យទុកដាក់ដល់អ្នកក្រីក្រ ប៉ុន្ដែសួរថា អ្វីទៅដែលបណ្ដាលអោយមានអំពើអយុត្តិធម៌និងភាពក្រីក្រតាំងតែពីដំបូងមក? គឺបាប *របស់បុគ្គលនីមួយៗ* និងភាពងងឹតនៅក្នុងចិត្តរបស់ *មនុស្ស* នោះឯង តែទស្សនៈនោះមិនមើលឃើញនូវបញ្ហានោះជាចំបងនោះទេ។ បញ្ហាមួយទៀតគឺ តាមទស្សនៈនេះដំណឹងល្អដោះស្រាយបញ្ហាដែលមកពីបាបរបស់អ្នកដទៃ មិនមែនបាបរបស់ខ្លួនឯងទេ ដូច្នេះដំណឹងល្អនេះមិនត្រាស់ហៅឲ្យមនុស្សប្រែចិត្តបែរចេញពីបាបរបស់ខ្លួនឡើយ។ បញ្ហាមួយទៀតនឹងទស្សនៈនេះគឺថា ទស្សនៈនេះបានបង្វែរអោយដំណឹងល្អ

ក្លាយជាដំណឹងល្អសំរាប់តែមនុស្សក្រីក្រខាងសាច់ឈាមនិងអ្នកដែលរងគ្រោះដោយសារអំពើអយុត្តិធម៌ប៉ុណ្ណោះ។ តាមពិត ព្រះមានព្រះទ័យទុកដាក់ចំពោះពួកគេ តែដំណឹងល្អក៏សំរាប់មនុស្សគ្រប់គ្នា ដោយមិនគិតថាអ្នកនោះមានស្ថានភាពនយោបាយសង្គមបែបណានោះឡើយ។

**សរុបសេចក្តី** ទស្សនៈខាងលើទាំងប៉ុន្មានសុទ្ធតែជាទស្សនៈយល់ខុសអំពីព្រះនិងទស្សនៈយល់ខុសអំពីមនុស្សដែលពោរពេញដោយអំពើបាប។ ហេតុដូច្នេះ គេក៏ខ្វះខាតការអំពាវនាវសំរាប់សេចក្តីត្រូវការអោយមានកំណើតជាថ្មី ហើយដោយហេតុនោះគេក៏មិនអាចសំរេចតាមគោលបំណងរបស់គេដែរ។

## *ការសុគតដើម្បីរំលោះបាប (ធួននឹងបាប) នាំអោយជំនឿគ្រីស្ទបរិស័ទខុសស្រឡះពីសាសនាដទៃ* How the Atonement sets Christianity as completely different from other religions

សាសនាទាំងអស់ក្នុងពិភពលោកសុទ្ធតែប្រាប់អោយមនុស្សខិតខំរកមធ្យោបាយទៅស្ថានសួគ៌ដោយសារទង្វើល្អរបស់ខ្លួន។ ការសុគតរបស់ព្រះយេស៊ូវបង្ហាញថាជំនឿរបស់យើងខុសគ្នាពីគេទាំងស្រុង។ បើសិនជាមនុស្សអាចរកផ្លូវទៅស្ថានសួគ៌បានមែននោះ ការសុគតរបស់ព្រះយេស៊ូវពិតជាអត់មានប្រយោជន៍ទាំងស្រុងហើយ។ ដង្វាយលោះបាបរបស់ទ្រង់គឺជាសារយ៉ាងជាក់ច្បាស់ថា យើងមិនមានលទ្ធភាពក្នុងការស្វែងរកផ្លូវទៅនគរស្ថានសួគ៌ដោយខ្លួនឯងបានឡើយ។ សាសនាដទៃទាំងឡាយខិតខំរកផ្លូវទៅស្ថានសួគ៌។ សាសនាទាំងនោះប្រកាសថា យើងត្រូវតែខិតខំដោយទង្វើខ្លួនឯង តែដំណឹងល្អប្រាប់ថា ព្រះយេស៊ូវបានធ្វើរួចរាល់អស់ទៅហើយ។

## *កិច្ចការ (សមិទ្ធផល) ផ្សេងទៀតរបស់ឈើឆ្កាង* Other Works of the Cross

សូមអានអត្ថបទខាងក្រោមដើម្បីរៀនអំពីសមិទ្ធផលផ្សេងទៀតរបស់ឈើឆ្កាង

យ៉ូហាន ១៤:៣១

១កូរិន. ១:១៨-២៥

ភីលីព ២:៥-១១

## *ការអនុវត្តន៍៖ អធិប្បាយអំពីឈើឆ្កាង* Application: Preach the Cross

តើខគម្ពីរខាងក្រោមទូន្មានគ្រូអធិប្បាយយ៉ាងណាខ្លះ?

១កូរិន. ៩:១៦

២កូរិន. ៤:៥ និង ១កូរិន. ២:១-៥

កាឡាទី ៦:១២-១៤

២កូរិនថូស ៥:១១-២១

### *ការអនុវត្តន៍៖ ដើរតាមផ្លូវនៃឈើឆ្កាង* Application: Follow the Way of the Cross

តើខគម្ពីរខាងក្រោមបង្គាប់គ្រីស្ទបរិស័ទធ្វើអ្វី?
ម៉ាថាយ ១០:៣៨

### *ការអនុវត្តន៍៖ ចូរសរសើរតម្កើងព្រះជាម្ចាស់ពីព្រោះទ្រង់សម្រុះសំរួលយើងអោយជានានឹងព្រះអង្គវិញដោយសារព្រះគ្រីស្ទ* Application: Praise God because he has reconciled us through Christ